ការិយាល័យកណ្តាល

អេស៊ីលីដា ACLEDA BANK

# សេចក្តីជូនដំណឹង

## ស្តីពី

# ការបែងចែកភាគលាភ

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេច នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៣ របស់ធនាគារ អេស៊ីលីដា នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ ធនាគារ អេស៊ីលីដា សម្រេចបែងចែកភាគលាភ សម្រាប់ប្រាក់ចំណេញក្នុងឆ្នាំ២០២២ ជូនដល់ភាគហ៊ុនិករបស់ធនាគារ អេស៊ីលីដា ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ប្រភេទភាគលាភដែលត្រូវបែងចែក | : **សាច់ប្រាក់** |
| ២. | រយៈពេល នៃភាគលាភ | : **ប្រចាំឆ្នាំ** |
| ៣. | អនុបាត នៃការបែងចែកភាគលាភ | : **៤០%** |
| ៤. | ភាគលាភសរុបដែលត្រូវបែងចែក | : **២៩៧.១០៥.៨៦៤.៩៨៧,៥៨ រៀល** |
| ៥. | ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | : **៦៨៥,៨៩៨៥ រៀល** |
| ៦. | កាលបរិច្ឆេទអិចឌីវីដិនដ៍ | : **ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣** |
| ៧. | កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលភាគលាភ (កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ) | : **ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣** |
| ៨. | កាលបរិច្ឆេទទូទាត់ភាគលាភ | : **ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣** |

**<u>បញ្ជាក់</u>៖**

- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភដូចការកំណត់ខាងលើ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក (Record Date) នៅ**ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣**។
- ភាគហ៊ុនិកដែល**លក់**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣** គឺ**នៅតែមានសិទ្ធិ**ទទួលបានភាគលាភនេះដដែល។
- ភាគហ៊ុនិកដែល**ទិញ**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣** គឺ**មិនមានសិទ្ធិ**ទទួលបានភាគលាភនេះទេ។
- ការទូទាត់ភាគលាភនឹងចាប់ផ្តើមពី**ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣** នៅរៀងរាល់ថ្ងៃធ្វើការ។


អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

សម្រាប់ព័ត៌មានបន្ថែម សូមធ្វើទំនាក់ទំនងមកធនាគារ អេស៊ីលីដា តាមរយៈអាសយដ្ឋាន និងលេខទូរស័ព្ទ ដូចខាងក្រោម៖

- **អាសយដ្ឋាន:** អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- លោក ហួត សុភី ប្រធានផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh
- លោក កែន រិទ្ធពុទ្ធា អ្នកឯកទេសបឋមប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
  - អ៊ីម៉ែល: ken.rithputhea@acledabank.com.kh
- លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ បុគ្គលិកជាន់ខ្ពស់ផ្នែកប្រតិបត្តិការ RTP
  - ទូរស័ព្ទ: (៨៥៥) ៦១ ២៨៧ ៧៦៦
  - អ៊ីម៉ែល: op.rtp@acledabank.com.kh

ថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**